កម្រងរឿងផ្អែកមនោសញ្ចេតនា

# អូនជាទេវី

និពន្ធដោយ ភាំណេល

គ~ស ១៩៧៤

បោះពុម្ពផ្សាយជាថ្មីដោយ

លោក ស្រី ប៊ុនជន

ភ្នំពេញ ថ្ងៃទី ១ កុម្ភៈ ២០០៥

# កំណត់អ្នកបោះពុម្ពផ្សាយ

យើងខ្ញុំទាំងបីយុវសិស្ស បេង បូរ៉ាត់, សរ ឆេងលី និង តាន់ សុខសេរី ជាអ្នកចាត់ចែងបោះពុម្ពផ្សាយរឿង "អូនជាទេវី"សូមអភ័យទោសពីសំណាក់អ្នកអានទាំងអស់ ពីលក្ខណៈមិនសមរម្យក្នុងការបោះពុម្ពផ្សាយនេះ ។

លោកអ្នកសឹងបានជ្រាបស្រាប់ហើយថា សព្វថ្ងៃទំនិញឡើងថ្លៃ ប្រាក់រកបានដោយក្រ រីឯសម្ភារៈបោះពុម្ព ក៏ឡើងថ្លៃខ្ពស់ អាចនឹងប៉ះពាល់យ៉ាងខ្លាំងដល់អ្នកអាន ។ កត្តាទាំងនេះហើយ ដែលបង្ខំឱ្យយើងខ្ញុំ បោះពុម្ពសៀវភៅនេះ ជាខ្សែៗស្តើងៗ ប្រហែលជា ២ ឬ ៣ ខ្សែ ថ្លៃលក់ទៀតសោត ក៏ថោកល្មមគួរសម ។

យើងខ្ញុំសូមអរគុណជាពន្លឹក ដល់អ្នកនិពន្ធដែលបានបង្ហាត់បង្ហាញយើងខ្ញុំ ឱ្យស្គាល់នូវតម្លៃអក្សរសាស្ត្រ វប្បធម៌ និងសិល្បៈខ្មែរ ហើយទុកចិត្តយើងខ្ញុំឱ្យបោះពុម្ពផ្សាយ រឿងនេះ និងសូមថ្លែងអំណរគុណជាអនេកកប្បការ ដល់លោកគ្រូជាទីគោរពនិងជាទីស្រឡាញ់ ដែលបានផ្តល់ចំណេះវិជ្ជា គ្រប់បែបយ៉ាងដល់យើងខ្ញុំទាំងអស់គ្នា

**យុវសិស្សទាំងបី**

## វាចាអ្នកនិពន្ធ

សូមឧទ្ទិសចំពោះមិត្តខ្ញុំម្នាក់ ដែលមានរឿងរ៉ាវអតីតកាល ដូច្នេះ....

សូមឧទ្ទិសចំពោះបងប្អូនខ្មែរភាគច្រើន ដែលកំពុងជួបទុក្ខវេទនា ក្នុងឱកាសស្រុកមានសង្គ្រាម ។

ខ្ញុំដឹងថារឿង **អូនខារធេវី** នេះ មិនជាទីគាប់ចិត្តដល់ជនមួយក្តាប់តូច ដែលរកស៊ីចំណេញកាត់កប ក្នុងពេលមានសង្គ្រាមនេះ គឺជាជនកញ្ជះទមិឡ ចោរឈ្នានពាន សត្រូវសួរពូជរបស់ខ្មែរ......

រឿងនេះមានទាក់ទងជាច្រើន ដល់អំពើឧក្រិដ្ឋនៃជនទាំងប៉ុន្មានប្រភេទខាងលើនេះ ។

សូមអរគុណ ចំពោះយុវជនទាំងបីរូបខាងលើ ដែលចាត់ចែងឱ្យប្រលោមលោកនេះ លេចជារូបរាងឡើង ។

ខែមិថុនា ១៩៧៤

**ភាណែណល**

# ១

# និស្ស័យពីព្រេង

ឆ្នាំ ១៩៦៩

ឆ្នាំនេះខ្ញុំជានិស្សិតឆ្នាំទី ៤ នៅមហាវិទ្យាល័យបុរាណវិទ្យា នៃសកលវិទ្យាល័យវិចិត្រសិល្បៈ

ខែមិថុនា មហាវិស្សមកាលបានចាប់ផ្តើម ខ្ញុំបានទៅដល់ខេត្តសៀមរាប ទឹកដីដែលសំបូរទៅដោយប្រាសាទបុរាណ ដើម្បីប្រមូលឯកសារ សរសេរនិក្ខេបបទមួយ មុននឹងចេញពីសាលា ។

មួយអាទិត្យកន្លងមកហើយ មួយអាទិត្យដ៏មានន័យបំផុតសម្រាប់ខ្ញុំ និងសម្រាប់កិច្ចការរបស់ខ្ញុំ បានកន្លងផុតទៅយ៉ាងឆាប់រហ័ស ។ មួយថ្ងៃៗខ្ញុំបង្កប់ខ្លួននៅកំផែងប្រាសាទ ពុំនោះសោតទេ ខ្ញុំទៅជួបលោកហ្គ្រោសីយេ.... ដើម្បីសាកសួរពត៌មានទាំងឡាយដែលទាក់ទងនឹងប្រាសាទទាំងនេះ។ យប់ៗ

ជូននៅក្នុងវត្ត. ជូននៅក្នុងបណ្ណាល័យខេត្ត ខ្ញុំអង្គុយសរសេរនិក្ខេបបទរហូតដល់យប់ជ្រៅ ។

ល្ងាចថ្ងៃសៅរ៍ ខ្ញុំក៏ដាច់ចិត្តសម្រាកកិច្ចការ មួយរយៈសិន ព្រោះខ្ញុំបានណាត់ពេលទៅលេងផ្ទះដូនម៉ែនមួយយប់ថ្ងៃសៅរ៍នេះ និងមួយថ្ងៃអាទិត្យទៀត ។ ដូនម៉ែន ជាអ្នកមានទ្រព្យបង្គួរម្នាក់ ដែលខ្ញុំទើបនឹងស្គាល់គាត់ នៅពេលថ្មីៗនេះឯង ។ ខ្ញុំបានជួបគាត់ជាលើកដំបូង ក្នុងពេលធ្វើដំណើរតាមរថយន្ត ពីភ្នំពេញមកសៀមរាប ។ ក្នុងផ្លូវដ៏វែងនេះ ដូនម៉ែនបានសាកសួរពីមុខងារខ្ញុំ សួរពីអ្វីៗទៀតជាច្រើន រហូតដល់គាត់រាប់អានខ្ញុំ ។ ខ្ញុំក៏ដូច្នោះដែរ ជួបគាត់លើកដំបូង ខ្ញុំមានអារម្មណ៍យ៉ាងល្អ ទៅលើគ្រួសារគាត់ ។ គាត់មានអាយុជាងហាសិបឆ្នាំ ហើយមេម៉ាយមានកូនបួននាក់ ។ កូនស្រីច្បងមានប្ដីពាក់សក្តិពីនៅតុលាការសឹកឯភ្នំពេញ កូនប្រុសបន្ទាប់មានប្រពន្ធហើយផ្លាស់ទៅធ្វើការនៅឯកំពង់ចាម ។ សព្វថ្ងៃ គាត់នៅសល់កូនប្រុសពីរនាក់ទៀតក្នុងបន្ទុក ដែលម្នាក់ទើបរៀនដល់ថ្នាក់ទី ៥ និងម្នាក់ទៀត រៀននៅបឋមសិក្សានៅឡើយ ។ គាត់ជាគ្រូរបាំបូរាណ ដែលចេះចាំជ្រៅជ្រះគ្រាន់បើ ពីសិល្បៈ



ខ្មែរ ។ គ្រួសារដ៏មធ្យមនេះនៅត្រើយខាងត្បូងឈៀងខាងលិចនៃចំណតរថយន្ត ។ ក្រោយពីបាយល្ងាចរួចហើយ ខ្ញុំបានទៅសម្រាកក្នុងបន្ទប់តូចមួយ ដែលមានបង្អួចបែរទៅខាងកើត ។

យប់ងងឹតបន្តិចហើយ ខ្ញុំច្រត់ដៃលើរបាបង្អួចមើលទៅក្រៅ ។ ដើមដូង. ដើមស្លាច្រូងច្រាង ពាសពេញភូមិ, ដើមម៉ាក់ប្រេង ម៉ាក់ប្រាង ដើមទឹកដោះ មានមែកត្រឈឹងត្រឈៃធ្វើឱ្យទេសភាពនៅរាត្រីនេះ រិតតែស្ងប់ស្ងាត់ថែមទៀត ។ តែដោយរាត្រីខែភ្លឺ ខ្ញុំមិនអាចមើលឃើញទេសភាពរៀងអាយនេះដោយជក់អារម្មណ៍ឡើយ ។

នៅជាប់របងខាងកើតផ្ទះ ដូនម៉ែន មានផ្ទះមួយទៀតដែលបានធ្វើអារម្មណ៍ខ្ញុំឱ្យព្រឺខ្លាច ។ នោះគឺផ្ទះឈើមួយខ្នងធំសង់បែបផ្ទះខ្មែរបូរាណ នៅក្នុងភូមិមួយដ៏ស្ងាត់ ។ ដើមដូងដើមស្លាណែនណាន់ក្នុងភូមិ ដូចផ្ទះ ដូនម៉ែន ដែរ តែខាងក្នុងមានសភាពស្ងាត់ជ្រងំ ដោយមានតែកូនអំពូលអគ្គិសនីតូចមួយប៉ុណ្ណោះ ដែលឆេះភ្លឺក្នុងល្វែងធំ ។ គេមិនឮសម្លេងក្មេងយំ ឬចាស់ៗ ជជែកគ្នា នៅក្នុងគ្រឹះស្ថានដ៏ធំនេះឡើយ ។ ម្ចាស់ផ្ទះទៅណាបាត់អស់ទៅហ្ន៎ ?

អុំះ! ស្រមោលស្រីម្នាក់ដើរចេញមកដល់ចំហៀងខាងកើតនៃរានហាល។ ស្រមោលនោះឈប់ស្ងៀម ។ ដៃនាងកាន់ធូបបីសរសៃ ដែលដុតជាស្រេច ។ នាងកាន់ធូបទាំងបីសរសៃនេះដោយដៃទាំងពីរ ហើយលើកផុតក្បាល. នាងអធិដ្ឋាន រួចដោតលើជើងធូបដែលនៅក្នុងស្តូបតូច ។ នាងថយមួយជំហានហើយលើកដៃប្រណម្យដ៏ល្អ ផ្ចិតផ្ចង់សង្រួមអារម្មណ៍ យ៉ាងគោរព ។ នាងជាកូនចៅនរណាទៅហ្ន៎ ! ក៏ស្រគត់ស្រគំស្គាល់ខុស ស្គាល់ត្រូវ ស្គាល់បាប ស្គាល់បុណ្យអីម្ល៉េះទេ ? ភ្នែកខ្ញុំតាមមើលកាយវិការនាងជាប់ជានិច្ច... នាងនៅក្មេងសក់វែងប្រាសស្មា តែរង្វង់មុខនិងទឹកមុខនាង ខ្ញុំមើលពុំច្បាស់ឡើយ ។

ការប្រតិបត្តិសក្ការៈបូជានេះហើយ ស្រីតូចដ៏សុភាពចុះជណ្ដើរ ហើយទៅអង្គុយលើអង្រឹងឈើមួយ ក្រោមដើមចំប៉ា ខាងកៀនរបងជាប់របងផ្ទះ ម្ហូនម៉ែន ។ ក្លិនចំប៉ាក្នុងរាត្រីក្រអូបល្ហឹងល្ហើយហាក់ដូចជាទេវតាប្រោះព្រំកញ្ញា តូចនេះ ។

ឱ រាត្រី ! រាត្រីនេះអីក៏មានន័យម្ល៉េះ ?

អង្រឹងឈើ មានចលនាទៅមុខទៅក្រោយ កំពុងជក់អារម្មណ៍រាត្រីខែភ្លឺនេះដែរ..... ។



ខ្ញុំដកដង្ហើមធំ ចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើស្រីតូចដ៏ភិសម័យនេះ ចង់ដឹងថានាងឈ្មោះអី ? ជាកូនចៅអ្នកណា ? ហេតុអីក៏ផ្ទះដ៏ធំរបស់នាងនេះ ស្ងាត់ស្ងៀមម្ល៉េះ ?

ពេលនេះ ម្ហូនម៉ែន ចូលមកដល់បន្ទប់ ដើម្បីយកខ្នើយនិងភួយមកឱ្យខ្ញុំ គាត់ងាកមកអើតតាមបង្អួច ទៅទិសដែលខ្ញុំសម្លឹងមើលទៅ ...

- នាងជាកូនស្រីតែមួយរបស់ចៅហ្វាយថង ។ ហឺ ! នាងជាកូនកំព្រាគួរឱ្យអាណិតណាស់ ។ តាំងពីឪពុកនាងស្លាប់ទៅ នាងរស់នៅតែជាមួយមេដោះដែលត្រូវជាម្ដាយមីងបង្កើតរបស់នាង ! ជារឿងមួយដ៏ចៃដន្យ ដែលពុំគួរឱ្យខ្ញុំចង់ដឹងទេ តែខ្ញុំក៏មិនយល់ដែរថា តើហេតុអ្វីបានជាពេលនេះ នាំចិត្តខ្ញុំឱ្យចាប់ភ្លឹកដល់នាងកំព្រានេះ ?

- ខ្ញុំមើលទៅនាងបែបអផ្សុកណាស់មែនទេ លោកអ៊ុំ?

- ពិតដូច្នេះហើយ ។ ផ្ទះធំល្វឹងល្វើយនេះ ជាកេររបស់ឪពុកនាងទុកឱ្យ ហើយគ្មាននរណាហ៊ានមើលងាយដល់នាងទេ ព្រោះកាលពីដើមគេរាប់អាននិងគោរពឪពុកនាងណាស់ ។ ផ្ទះធំយ៉ាងហ្នឹងនាងនៅជាមួយមេដោះ .....

- យី លោកអ៊ំ! ខ្ញុំហាក់ដូចជាចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើនាង ......។ កាលពីដើមឪពុកនាងធ្វើការអីដែរ ?

- ធ្វើចៅហ្វាយស្រុក។ លោកចៅហ្វាយ ថង យល់ទុក្ខធុរៈគេណាស់. ធ្លាប់ជួយសង្គ្រោះមនុស្សជាច្រើន កាលសម័យដាបឈូន ។ គាត់ស្លាប់ជាងបួនឆ្នាំហើយ ដោយលិចកាណូតនៅទន្លេសាប ។ លោកស្រីជាប្រពន្ធចៅហ្វាយ ថង បានខូចតាំងពីស្រីកែវ នៅតូចម្ល៉េះ !

ខ្ញុំបន្ទរខ្សល់ដង្ហើមតាមមាត់ ខ្ញុំក៏អាចស្គាល់ឈ្មោះស្រីតូចសុភាពនេះទៀត .... ស្រីកែវ ឈ្មោះក៏ល្អ ក៏ពីរោះ ក៏សុភាពក៏ ......។

" គ្មាននរណាហ៊ានមើលងាយដល់នាងទេ ព្រោះកាលពីដើម គេរាប់អាននិងគោរពឪពុកនាងណាស់ ។ គាត់ធ្លាប់ជួយសង្គ្រោះមនុស្សជាច្រើន..... " ។

ឃ្លាមួនម៉ែនអាចឱ្យខ្ញុំកាត់យល់បានយ៉ាងច្រើននូវកុសលដែលមានក្នុងគ្រួសារដ៏ល្អនេះ ។

ចំជាវិសេសមែន! លោកចៅហ្វាយ ថង ហាក់បានសាងកំពែងមួយ សម្រាប់ការពារកូនស្រីលោកជាស្រេច មុននឹង



លោកអនិច្ចកម្មទៅ ជាកំពូលឪពុកដែលកូនទាំងឡាយបានជួបជាតិនេះហើយ តែងប្រាថ្នាឱ្យជួបជាតិក្រោយទៀត ។ ប្រសិនជាកាលនៅរស់ ចៅហ្វាយ ថង យកអំណាចចៅហ្វាយស្រុកទៅជិះជាន់គេ ដូចអ្នកខ្លះទៀតនោះ ម្ល៉េះមិនដឹងជាវាសនា ស្រីកែវតូចល្អទៅជាយ៉ាងណាទេ? មិនដឹងជាមានសត្រូវប៉ងយាយីសងសឹកយ៉ាងណាទេ សមនាងជាស្រីឯកាដូច្នោះផង ។

មួនម៉ែន ចូលមកម្តងទៀត ដោយកាន់ទាំងចង្កៀងនិងកញ្ចប់រូបថតមកផង ។ ខ្ញុំបែរទៅ គាត់ចាប់ផ្តើមបង្ហាញថា :

- នេះរូបនាង. ថតជាមួយមីកូនខ្ញុំ ។ ទឹកមុខនាងគួរឱ្យស្រឡាញ់ណាស់ ។ ថ្ងៃណាទំនេរ នាងតែងឱ្យអ៊ំបង្រៀននាងរាំ ។ រៀងរាល់ឆ្នាំ ទោះកាលឪពុកនាងនៅរស់ក្តី នៅផ្ទះនាងតែងតែមានធ្វើបុណ្យ ។ នៅពេលធ្វើបុណ្យ ឬនៅពេលចូលឆ្នាំលោកតែងបរិច្ចាគទ្រព្យធនខ្លះ ចែកចាយដល់ជនខ្សត់ខ្សោយ។ នៅពេលនោះ នាងតែងតែចេញរាំជូនគេឯងមើលកំសាន្ត ជាមួយវង់របាំអ៊ំ ។ ក្រុមត្រុដិនៅសៀមរាប តែងទៅដល់ផ្ទះនាងមុនគេនៅពេលចូលឆ្នាំម្តងៗ ពតិមាននេះរឹតតែធ្វើឱ្យចាប់ចិត្តទៅលើនាងខ្លាំងថែមទៀត ។

- ល្អណាស់ ! វង់មុខនាងគួរឱ្យស្រលាញ់ណាស់ ។ នាងល្អដូចទេពអប្សរលើជញ្ជាំងអង្គរ( ខ្ញុំនិយាយដោយមិនដឹងខ្លួន)

ខ្ញុំដឹងថា **ម៉ូនម៉ែន** កំពុងសម្លឹងមុខខ្ញុំ ក្នុងន័យមួយសែនពិបាកកាត់យល់នូវទឹកចិត្តគាត់ ។ ឬមួយគាត់យល់ថាខ្ញុំឡេបខាយឱ្យកូនរបាំគាត់ ។ ដើម្បីបន្ធូបបរិយាកាសដ៏តឹងតែងនេះ ខ្ញុំចាប់ផ្តើមសួរគាត់ថា :

- នាងបានរៀននឹងគេដែរទេ ? លោកអ៊ំ ?

**ម៉ូនម៉ែន** ឆ្លើយយ៉ាងប្រញាប់ ហាក់ដូចជារង់ចាំសំណួរនេះជាយូរមកហើយ ។

- រៀន ! រៀនដល់ថ្នាក់ណានោះខ្ញុំមិនដឹងទេ តែឮថាដល់ចូលកងនេះហើយ នាងប្រឡងបាក់អីនោះហើយ !

- អ៊ូ ! អីចឹងនាងរៀនដល់ថ្នាក់ទី ២ ហើយ !

- ប្រហែលដល់នោះហើយមើលទៅ ព្រោះមិនសូវដឹងថ្នាក់ទីពីរ ទីដប់អីទេ ។

- ម្យ៉ាងទៀតចាស់ៗ នៅជិតខាងនាងដូចជាអ៊ំជាដើម នាងតែងហៅម៉ែៗទាំងអស់ ។ ម្ល៉ោះហើយអ្នកណាក៏ស្រឡាញ់នាងដូចកូនបង្កើតអីចឹងដែរ !



- អ៊ូ !

ខ្ញុំនៅស្ងៀមស្ងាត់យ៉ាងយូរ ព្រោះអារម្មណ៍មិនដឹងជាខ្ទាតចេញទៅណាបាត់ ។

- ក្មួយសំរាន្តចុះ .... យប់ណាស់ហើយ !

ខ្ញុំងើបមុខឡើង ។

- សុំអ៊ំទុករូបថតនេះ ឱ្យខ្ញុំមើលបន្តិចសិន។ ជម្រាបអ៊ំតាមត្រង់ទៅចុះ...ថាខ្ញុំ... ខ្ញុំ...ចាប់អារម្មណ៍ទៅលើសន្តានចិត្តដ៏ល្អរបស់ឪពុកនាង !

ខ្ញុំមិនហ៊ានមើលមុខអ៊ំ **ម៉ែន** ទេ ។

- ស្អែកឬខានស្អែក ក្មួយអាចឃើញនាងហើយ ។ ឯនាង នាងធ្លាប់ឃើញក្មួយពីរដងហើយ កាលក្មួយមកលេងផ្ទះអ៊ំលើកមុន ។

ខ្ញុំភ្ញាក់នឹងដំណឹងនេះទៀត ។

- ស្តាយដែរ ខ្ញុំមិនចាប់ភ្លឹកដល់រឿងអ្វីក្រៅពីប្រាសាទអង្គរសោះ តាំងពីមកដល់សៀមរាបដំបូងម្ល៉េះ ។

អ៊ំ **ម៉ែន** ចេញផុតទៅ ខ្ញុំស្ទុះទៅមាត់បង្អួចមើលទៅអង្រឹងដែល **កែវ** តូចស្រស់អង្គុយ ។ នាងទៅបាត់ ។ ផ្ទះដ៏ធំ

ជង្រ្គីងរបស់នាង បិទទ្វារពន្លត់ភ្លើងសូន្យឈឹង ឈរច្រងក់កណ្ដាលរាត្រី ដែលមានខ្យល់បក់រំភើយៗ ។ ខ្ញុំឈរត្រង់ខ្លួនសម្លឹងគ្រឹះស្ថាន ដែលកប់ទៅក្នុងកំណប់ពេជ្រមរកតដ៏ល្អ ជាសោភ័ណនៃមនុស្សក្នុងសកល ។ **ស្រីកែវ** ឆ្នើមស្រស់ប្របហែលគេងលក់ហើយ... សូមទេវតាអង្គរវត្ត ពន្យល់សប្តិល្អដល់នាង និងជួយគាំពារថែរក្សនាងឱ្យបានសេចក្ដីសុខរៀងទៅ ។

ខ្ញុំបិទបង្អួចប្រះគេងលើគ្រែ ដាក់ភ្លើងលើក្បាលដំណេកមើលរូបថត....។ ល្អមែន ! ល្អមែន ! ល្អទាំងចិត្តល្អទាំងកាយល្អទាំងពូជ ល្អទាំងពង្ស ... ។

ចាប់តាំងពីរាត្រីនោះមក ទឹកដីសៀមរាបកាន់តែមានន័យខ្លាំងឡើងៗ សម្រាប់ដួងចិត្តខ្ញុំ ផ្ទះ **ជូនម៉ែន** ដ៏មនោរម្យដែលធ្វើឱ្យបានឃើញនាងដំបូង ហើយបាននិយាយរកនាងរាប់អាននាង ។ ជីវិតខ្ញុំដែលកាលពីប៉ុន្មានឆ្នាំមុន ខ្ញុំតែងគិតថាជាជីវិតឥតន័យ, ឥតខ្លឹមសារ ឥឡូវជីវិតនេះពោរពេញទៅដោយទឹកដម ។ បានជួបនាង បាននិយាយរកនាងម្ដងៗ ខ្ញុំបានសុខក្នុងចិត្តណាស់ ហើយផ្ទះ **ជូនម៉ែន** ក៏ក្លាយទៅជាទីដែលខ្ញុំទៅមកញឹកញាប់មួយថ្ងៃបីបួនដង ដើម្បីបានឃើញមុខកញ្ញាតូចស្រស់, និយាយរកនាងតែមួយម៉ាត់ក៏អស់ចិត្តដែរ ។ នាងបានរាប់រកខ្ញុំយ៉ាងថ្លៃថ្នូរ ហើយ **ជូនម៉ែន** ក៏ទុកចិត្តខ្ញុំដូចមនុស្សក្នុងគ្រួសារគាត់ដែរ ធ្វើឱ្យខ្ញុំប្រិតប្រៀនជានិច្ច តាំងពីអាកប្បកិរិយាសំដីសំដៅឡើងទៅ ។ **ស្រីកែវ** រួសរាយមានទឹកមុខស្រស់ញញឹមជានិច្ច ព្រមដោយអាកប្បកិរិយារឹងប៉ឹង ម៉ឺងម៉ាត់សមជាកូនអ្នកមានពូជ មានអម្បូរណ៍ ។ នាងតែងសាកសួរខ្ញុំពីកិច្ចការខ្លះដែលនាងឆ្ងល់ ដូចជាបញ្ហាទាក់ទងទៅនឹងសង្គមមនុស្សទៅលើសិល្បៈជាដើម ។



កន្លះខែ ជារយៈពេលខ្លីបំផុត ក្នុងការដែលយើងស្គាល់គ្នា តែយើងបានរាប់អានគ្នាលើសពីស្គាល់គ្នាម្ភៃឆ្នាំទៅទៀត។ ខ្ញុំនឹកថានេះជានិស្ស័យពីព្រេងហើយ ... ហើយខ្ញុំក៏គ្មានបំណងអ្វីអាក្រក់ទៅលើនាងដែរ។ ខ្ញុំចូលចិត្តស្ដាប់នាងនិយាយ. នាងនិយាយអ្វីក៏និយាយចុះ ព្រោះសំដីនាងនិងសំឡេងនាងពិរោះអីម្ល៉េះទេ ។ អ្នកស្រុកសៀមរាបនិយាយពិរោះចម្លែកជាងអ្នកនៅខេត្តខណ្ឌណាៗ ទាំងអស់ក្នុងស្រុកខ្មែរ ។ ខ្ញុំក៏ចាប់ចេះស្រលាញ់ភាសាអ្នកសៀមរាបតាំងពីថ្ងៃនោះមក ។

គឺនៅទឹកដីសៀមរាបនេះឯង ដែលពន្លកស្នេហ៍ដ៏បរិ-

សុទ្ធពោរពេញទៅដោយាការស្រមៃ ដូចយល់សប្តិ៍បានចាប់កំណើតឡើង ។ ខ្ញុំកំពុងបានរស់ក្នុងពិភពមួយថ្មីស្រោចស្រពដោយលំអងស្នេហ៍ និងពិដោរទិព្វ នៃកូនភ្នែកមួយគូខ្សៀវស្រងាត់ ដូចផ្ទៃទឹកសមុទ្រនៃចំប៉ាសៀមរាប ... តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតដល់រឿងរ៉ាវនេះច្រើនយ៉ាងណា ក៏ខ្ញុំមិនហ៊ានបញ្ចេញឱ្យអ្នកណាដឹងដែរ ដែលជួនកាលខ្ញុំអង្គុយអណ្តែតអណ្តូងហើយដកដង្ហើមធំម្នាក់ឯង ...... គួរឱ្យល្អសើចមែន ។

# ២

# ខ្ញុំនិងនាង

នាងរាប់អាន ដូនម៉ែន ឬអ្នកជិតខាងយ៉ាងណា នាងក៏រាប់អានខ្ញុំយ៉ាងនោះដែរ ដោយគ្មានគិតថាខ្ញុំជាមនុស្សចំណូលថ្មីសោះឡើយ ។

រកគិតមិនយល់សោះ ថាតើអានុភាពដែល នាំឱ្យមានចិត្តទោរទន់ ហើយស្លូតបូតនៅចំពោះមុខកញ្ញាដ៏ស្រស់នៃខេត្តសៀមរាបនេះ? នឹកដល់រឿងអតីតកាល ឱ ! បើគិតដល់រឿងអតីតកាល ខ្ញុំត្រូវតែថយឱ្យឆ្ងាយពីនាង ព្រោះនាងជាទេពធីតាល្អគ្មានពីរក្នុងលោក ពុំគួរបើខ្ញុំដែលមានរឿងអតីតកាលខ្មៅស្មោកគ្រោកទៅនៅក្បែរនាងសោះ ។ នៅភ្នំពេញ កាលពីពីរបីឆ្នាំមុន..... ខ្ញុំធ្លាប់ទៅផ្ទុំត្រុំប៉ែតនៅក្នុងរង្គសាល ដើម្បីយកសោហ៊ុយបន្តិចបន្តួច ទិញសៀវភៅ និងផ្គត់ផ្គង់ក្រពះពេលរៀនសូត្រ។ របរផ្ទុំត្រុំប៉ែតក្នុងរង្គសាលផងរៀនសូត្រផង បាន

ធ្វើឱ្យខ្ញុំឈឺជាទម្ងន់ក្នុងឆ្នាំនោះ ហើយមានការខ្វះខាតយ៉ាងច្រើន ដោយខ្ញុំពុំមានឪពុកម្ដាយបងប្អូន ឬអ្នកអាណាព្យាបាលផ្ដួចផ្ដើមនឹងគេ ។ ដោយស្រឡាញ់ខ្ញុំ ដោយអាណិតខ្ញុំ ដោយស្អីមិនដឹង ស្រីក្នុងរង្គសាលម្នាក់បានផ្ដល់ប្រាក់កាសឱ្យខ្ញុំ ហើយឱ្យខ្ញុំនៅស្ងៀម ខំតែរៀនទៅចុះ ។ នាងនោះបានចិញ្ចឹមខ្ញុំ ហើយខ្ញុំក៏ឈប់ទៅផ្ដុំត្រៃក្នុងរង្គសាលហ្នឹងទៅ ដោយគ្រាន់តែពាក់កណ្ដាលអធ្រាត្រ. ពេលរង្គសាលរាំរោង ខ្ញុំជិះស៊ូឡិចទៅឱបនាងមកផ្ទះវិញ។ យើងជាសាហាយនឹងគ្នាព្រោះពាក្យប្ដីប្រពន្ធកាលណោះ ហាក់ដូចជាគ្មានន័យអ្វីបន្តិចសោះសម្រាប់យើង ។ នាងឈ្មោះរីណា តែនឹកថាឈ្មោះរីណានេះ ប្រហែលជាឈ្មោះក្រោយទើបតែប្រឌិតឡើង នៅពេលដែលនាងធ្លាក់ខ្លួនមកជានារីរង្គសាលទេ ។ ឯឈ្មោះដើមពីកំណើត ឪពុកម្ដាយដាក់ឈ្មោះឱ្យនោះ មិនដឹងយ៉ាងម៉េចឡើយ ឈ្មោះសុខក៏មិនដឹង សៅរ៍ក៏មិនដឹង ឬក៏ចេក ចាច ម៉ាច ម៉ៅ អីក៏មិនដឹងផង ។ ខ្ញុំរស់ដោយសារស្រីចិញ្ចឹម.... គួរឱ្យអាម៉ាស់មែន ។ នាងមានរូបស្រស់គ្រាន់បើ ។ ដូច្នេះហើយទើបនាងអាចកោរក្បាលអ្នកមានប្រាក់គ្រប់ធុនមកចិញ្ចឹមខ្ញុំ។ សាហាយរបស់នាងមានច្រើន



ណាស់ដែលខ្ញុំអាចស្គាល់ ខ្លះជានាម៉ឺននាសែនទៀតផង ។ ពួកនោះមិនដឹងជាទៅច្របាច់កអ្នកណាខ្លះទេ ដើម្បីយកលុយមកចាយដូចគេហែកចោលនៅក្នុងរង្គសាល ។ បានពីនេះមកចែកអ្នកនោះ.... រឿងនេះមិនខុសពីពាក្យចាស់ដែលថា បានពីក្អែកមកចែកតាវៅនោះទេ ។ រីណាថ្នមចិត្តខ្ញុំណាស់ ។ រឿងអ្វីក៏នាងមិនដែលលាក់នឹងខ្ញុំដែរ ។ ដូចជាថាយប់នេះនាងទៅដេកកំដរលោកនេះ លោកនោះ គេឱ្យប្រាក់នាងប៉ុណ្ណេះប៉ុណ្ណោះ ។ ថ្ងៃណានាងទៅកំដរគេផឹកស្រា កំដរគេស៊ីបាយហើយនាងតែងនិយាយជាញឹកញាប កុំឱ្យខ្ញុំចាប់ភ្លឹកដល់មុខរបររបស់នាងអី ។ មើលទៅនាង. នាងហាក់ដូចជាបញ្ចេញសមានចិត្តយ៉ាងច្រើនមកលើខ្ញុំ ហើយបង្ហាញឱ្យឃើញថា គ្មានសង្ឃឹមនឹងបានរួមរស់ជាមួយខ្ញុំអស់មួយជីវិតដែរ ។ នាងហាក់ដូចជា គ្រាន់តែចម្លងខ្ញុំឱ្យដល់ត្រើយ ក្នុងពេលប្រទះឃើញ កំពុងតែផុតជើងផុតដៃលិចលង់ក្នុងសាគរ ។

ទីបំផុត យើងទាំងពីរលែងជាសហាយស្មន់នឹងគ្នាទៀតហើយ ថ្វីត្បិតតែយើងនៅផ្ទះជាមួយគ្នាក៏ដោយ។ ខ្ញុំបានដាស់តឿននាង ឱ្យចាប់ផ្ដើមរៀបរយជីវិតជាថ្មីវិញ ព្រោះមុខរបរ

នេះ ពុំអាចធ្វើឱ្យនាងមានអនាគតភ្លឺស្វាងទេ ។ នាងតាមខ្ញុំ ។ ថ្ងៃ១ នាងទៅរៀនអង្គុលីលេខ ហើយមិនបានប៉ុន្មានខែក្រោយមក នាងក៏ក្លាយទៅជាស្មៀនក្នុងក្រុមហ៊ុនជំនួញមួយ ដែលខ្ញុំពឹងមិត្តភក្តិឱ្យជួយរកកន្លែងឱ្យនាងធ្វើការ ។ នាងផ្លាស់ជីវភាពហើយ ។ នាងបានអរគុណយ៉ាងច្រើនដល់ខ្ញុំ ។

ថ្ងៃមួយខ្ញុំមានកង្វល់ក្នុងចិត្តជាខ្លាំង ដោយបានដំណឹងថា ពួកយួនបានធ្វើបាបកាប់សម្លាប់ ជាតិខ្មែរក្រោមអស់ជាច្រើន មានស្ត្រី ក្មេង ចាស់ព្រមទាំងព្រះសង្ឃនៅភូមិក្នុងស្រុក (កម្ពុជាក្រោម) ទីដែលខ្ញុំធ្លាប់រស់នៅពីតូច ។ ខ្ញុំឈឺចាប់នឹងអំពើឧក្រិដ្ឋនេះជាខ្លាំង ហើយខ្ញុំរឹតតែឈឺចាប់ណាស់ទៅទៀតដោយឃើញខ្មែរកម្ពុជាកណ្តាលឯណោះ កំពុងសប្បាយភ្លើតភ្លើននឹងសន្តិភាពដ៏សំគមរបស់ខ្លួន ។ ខ្ញុំខឹង ខ្ញុំឈឺចាប់ ខ្ញុំរន្ធត់ចិត្ត តែខ្ញុំពុំអាចនិយាយរឿងនេះឱ្យនរណាស្តាប់ឡើយ ។ គ្មាននរណាជួយឈឺចាប់ខ្ញុំទេ ។ ដោយខ្វល់ពេក ល្ងាចនោះខ្ញុំញុំាស្រាយ៉ាងច្រើន....យ៉ាងឆិល... ស្រវឹងអស់ចិត្ត ។ ពេលព្រលប់ខ្ញុំមកដល់ផ្ទះទាំងដំណើរទទ្រេតទទ្រោត ក្តួតវើកវ៉ាកតាមផ្លូវយ៉ាងអនាថា ។ ឡើងដល់លើផ្ទះ **វីណា** កំពុងនិយាយជាមួយ



ប្រុសម្នាក់ ។ ចិត្តខ្ញុំឆេវមួយរំពេច ចិត្តធំសំបើមណាស់ហ្ន៎ ហ៊ាននាំប្រុសមកដល់ផ្ទះតែម្តង ។ ខ្ញុំស្តីឱ្យ **វីណា** យ៉ាងច្រើន ទាល់តែប្រុសនោះគេចទៅបាត់ជាបន្ទាន់ ។

ក្នុងពេលស្រវឹង ខ្ញុំពុំដឹងថាស្តីឱ្យ **វីណា** បែបណានោះផង ។ នាងតបតែមួយម៉ាត់មិនទាន់ផុតពីមាត់ផង ខ្ញុំទះនាងពីរបីដៃ ដួលច្រងាប់ច្រងិលទៅគ្រលៀតជញ្ជាំង ហើយខ្ញុំក៏ដេកលើគ្រែភ្លាមនោះទៅ ។ ខ្ញុំឮនាងយំ. នាងថាខ្ញុំកំរោលដូចគោ ដូច... ថា....ស្អី១ទៀត តែត្របកភ្នែកកាន់តែទន់ ហើយដេកលក់ភ្លាមឥតបង្អង់. ឥតរវល់. ឥតឮសម្លេងនាងទៀតទេ។ វិប្បដិសារី ! ខ្ញុំនឹកឃើញទាំងអស់នូវអ្វី១ធ្លាប់មានទំនាក់ទំនងជាមួយ។ ឱ ! គួរឱ្យស្តាយមែន ! ខ្ញុំជាមនុស្សកំរោលបួនជ្រុងមែន ។ នាងធ្លាប់បានចិញ្ចឹម ឧបត្ថម្ភខ្ញុំសព្វគ្រប់ទាំងអស់ ។ កាយវិការនេះ ចាត់ទុកថាជាស្រីចិញ្ចឹមប្រុស... ទឹកក្តៅ ទឹកត្រជាក់ !...សព្វយ៉ាងប្រៀបដូចប្រឡាំងកាសទៅហើយ ។ ដូចភាសាអ្នកក្រម៉ាច់ថា "ស៊ីលើគេ ដេកលើគេ" ខ្ញុំចង់សប្បាយសប្បាយ ចង់ផ្តាច់ការទាក់ទងគ្នាក៏ផ្តាច់ ។ **វីណា**គ្មានមាត់មួយអ៊ឹះ។ តាំងពីខ្ញុំទឹកដល់ច្រមុះរហូតរស់មួយជីវិត ព្រមទាំងរៀប

ចំស្ថានភាពជីវិតឱ្យប្រសើរបានបន្តិច ។ ដូចជាខ្ញុំប្រឹងរៀន នាង
មានមុខធ្វើជាលេខានៃក្រុមហ៊ុនមួយ ។

ដោយសារតែជាតិសុរានិងក្តីប្រច័ណ្ឌ ធ្វើឱ្យខ្ញុំឆ្កួតមួយ
រំពេច ទោះបីដឹងថា នាងលែងទាក់ទងផ្លូវភេទជាមួយនឹងខ្ញុំក៏
ដោយ ។ ខ្ញុំស្រវឹង ! ខ្ញុំឆ្កួត ! ខ្ញុំឃោរឃៅដូចសត្វ ព្រោះបាត់
បង់សតិនិងវិចារណញ្ញាណ ។ ខ្ញុំមិនគួរវាយធ្វើបាបនាងសោះ
នាងជាស្រីបារ ជាស្រីបម្រើផ្លូវភេទមែន តែនាងមានកិរិយា
មារយាទយល់ដឹងខ្លះៗដែរ ។ រឿងអាស្រូវដែលនាង វីណា
ប្រព្រឹត្តនិងទទួលយកសព្វថ្ងៃនេះ មកពីបញ្ហាទាល់ច្រក និង
ស្ថានភាពសង្គម មិនមែនដុះឡើងពីចិត្តនាងទេ ។ ថ្ងៃ ខែ ឆ្នាំ
ចេះតែកន្លងផុត ។ ភាពអាស្រូវរបស់នាង កាន់តែត្រូវបានកែ
លម្អ ។ ថៅកែក្រុមហ៊ុនមានសេចក្តីទុកចិត្តលើនាង ។ ទំនាក់
ទំនងស្នេហាជាមួយនាង **វីណា** តាមបែប "ជិះក្របីចម្លងផុក"
ក៏កាន់តែឆ្ងាយទៅៗ ។ ដោយសារភាពស្មោះត្រង់ សកម្មក្នុង
ការងារ ហើយមានចិត្តអំណត់ផងនោះ.... នាងត្រូវបានប្រធាន
ក្រុនហ៊ុន បញ្ជូនទៅធ្វើការជាមួយប្អូនស្រីបង្កើតឯស្រុកបារាំង
ក្នុងឋានៈជាកម្មករ បម្រើការក្នុងអាហារដ្ឋាន នៅស្រុកបារាំង



នាងមានសិទ្ធិសេរីភាពគ្រាន់បើ ។ អតីតកាលដ៏ជូរចត់ អា-
កប្បកិរិយាដ៏រាត់រាយ នាងខិតខំជម្រុះជម្រះជាបណ្តើរៗហើយ
នាងខិតខំបំភ្លេចរឿងរ៉ាវជាមួយនិស្សិតនោះឱ្យអស់ តែបិសាច
ស្នេហា ចេះតែមកលងលេងម្តងម្កាល.....។ តែទីបញ្ចប់ នាង
សម្រេចចិត្តការប្តីបារាំងទៅ ។ នាងរស់នៅបានសុខហើយ ។

"ដីរស្លាប់កុំយកចង្កេរ" ទៅបាំង។ រឿងរ៉ាវនៅភ្នំពេញ
បានលេចឮទៅដល់ខេត្តសៀមរាប ។ កេរ្តិ៍របស់ខ្ញុំ ស្អុយរហ៊ុំ
ចំពោះមុខអ៊ំ **ម៉ែន** និង **កែវតូច** ។ តែគេទាំងពីរធ្វើធម្មតាដូច
ជាមិនដឹងអ្វីសោះ។ ប្រហែលជាពួកគាត់គិតថាស្នេហាមុនបែក
ឆ្ងាយ ឆ្ងាយ....ហៅលែងឮ ហើយមិនកើតឡើងថ្មីទៀតទេ ។

តែចំពោះខ្ញុំ ខ្ញុំចង់ដកចិត្តចេញពីនាង ព្រោះទីមួយ គេ
ដឹងរឿងអាក្រក់របស់ខ្ញុំ ។ ទីពីរ ស្ថានភាពគ្រួសារខ្ញុំ សម្បុក
សម្បត្តិខ្ញុំនឹងគេខុសគ្នាឆ្ងាយណាស់ ដូចមេឃនិងដី ។

ម្ល៉ោះហើយខ្ញុំចេះនឹកថា ខ្ញុំបានស្គាល់នាងហើយនាងក៏
បានរាប់អានខ្ញុំដោយស្មោះស្ម័គ្រ ហើយខ្ញុំបែរជាព្យាយាមគេច
ពីនាងរហូតព្រោះពេលជួបនាងម្តងៗទ្រូងខ្ញុំញ័រចំប្រប់ បេះដូង
កញ្ច្រោលស្ទើរធ្លាយទ្រូង ។ កុំជួបមុខនាងឱ្យសោះ ប្រយោជន៍

កុំឱ្យកកើតជាស្នេហាអ៊ីទៅលើនាង ។ មែន ! ខ្ញុំស្រឡាញ់នាង តែស្ថានភាពខ្ញុំនិងនាងខុសគ្នាឆ្ងាយពេក ។ ដូច្នេះខ្ញុំត្រូវតែគេចមុខ ដើម្បីឱ្យសេហ្នាអាថិកំបាំងក្នុងបេះដូងខ្ញុំនេះ អាចរលត់បាត់ទៅដោយឯង១ ។ ខ្ញុំថយទៅរកដំណេកពួន ឯវត្តដំណាក់វិញ ។ ព្រឹកស្អែកថ្ងៃអាទិត្យ ស្រួលមិនស្រួល ខ្ញុំនឹងទៅដល់ភ្នំគូលេនតែម្តង បើសិនជាមានមធ្យោបាយ ។ ល្ងាចនេះ ខ្ញុំគេងដោយគ្មានបានមើលសេចក្តីព្រាងនិក្ខេបបទ ដែលខ្ញុំស្រាវជ្រាវបានពីថ្ងៃឡើយ ។ ណ្ហើយ ! ស្អែកថ្ងៃអាទិត្យ ខានស្អែកថ្ងៃច័ន្ទក៏អាចទំនេរបានដែរ ព្រោះការស្រាវជ្រាវនេះ មានរយៈពេលយូរខែទៅមុខទៀត ។

ពេលយប់. អាកាសនៅសៀមរាបត្រជាក់បន្តិចព្រោះមានដើមឈើច្រើន ។ ខ្ញុំគ្រលំភួយ ស្រាប់តែសូរមាត់ស្រីម្នាក់នៅខាងក្រៅ ដែលខ្ញុំឮសំឡេងព្រះគ្រូអនុគុណ :

- ទេ ! ពីក្បាលល្ងាច អាត្មាឃើញមួយភ្លែតដែរ. បែបទៅមើលបុណ្យទាននឹងគេបាត់ទៅហើយក៏មិនដឹង !

ខ្ញុំស្ទុះក្រោកឡើងហើយចេញមក ។ លោកគ្រូអនុគុណលាន់ព្រះឱស្ឋថា :



- នុំះ វ៉ាត អាត្មាស្មានតែទៅណាបាត់ទៅហើយ !

គឺ ងួនម៉ែន ។ ខ្ញុំរកពាក្យនិយាយជាមួយ ងួនម៉ែន មិនទាន់ តែគាត់រហ័សប្រាប់ពតិមានភ្លាមថា :

- ស្រីកែវ ឱ្យខ្ញុំតាមរកក្មួយពីរបីថ្ងៃហើយ រកមិនជួបសោះ ។ កែវ ចង់ជួបនឹងក្មួយ !

- លោកអ៊ំ មានដឹងថា កែវ ចង់ជួបខ្ញុំមានការអីទេ ?

- អ៊ំមិនដឹងទេ តែប្រហែលជាមានការពិសេសហើយ ព្រោះនាងទន្ទេញតែចង់ជួបក្មួយពីរបីថ្ងៃមកហើយ !

- ជួបថ្ងៃណា ? ស្អែកឬលោកអ៊ំ ?

- ទេ ល្ងាចហ្នឹង !

- យី មានការអីបន្ទាន់ណាស់ហ្ន៎ !

- ពីក្បាលល្ងាច អ៊ំមករកក្មួយម្តងហើយ ។ កែវ ចង់ឱ្យក្មួយទៅរួមក្នុងពិធីបុណ្យសង្ឃទាននោះដែរ តែរកក្មួយពុំជួបសោះ !

- អូ ! ខ្ញុំរវល់ទាល់តែយប់ពាក់បណ្តាលអធ្រាត្រ ទើបមកដល់កុដិវិញ ។ អ៊ំចាំមួយភ្លែត ខ្ញុំស្លៀកពាក់សិន ។

អាយ៉ងណាំងទ្រលុង នឹងលេងជូនសាធារណជនទស្សនា

រហូតទល់ភ្លឺ ។ សម្លេងសើចក្អាកក្អាយពីរោងរបាំ ធ្វើឱ្យកញ្ញា សប្បុរសសប្បាយរីករាយផងដែរ ។

រាត្រីកាន់តែយប់បន្តិចទៅហើយ ភ្ញៀវពន្លឺចាស់ទុំដែល បានមកជួយពិធីបុណ្យ ក៏រកកន្លែងសំរាកបន្ត១ គ្នា ។

កែវ និងខ្ញុំ អង្គុយជជែកគ្នាលេងនៅបន្ទប់ធំ ដែលពី ក្បាលល្ងាច ជាកន្លែងលោកសូត្រមន្ត ។ នៅក្បែរ១នោះ ឧបា-សិកាពីរបីនាក់កំពុងបុកស្លា និងខ្លះទៀតកំពុងទម្រេតតម្រង់ ខ្នង ដែលមានចៅតូចជួយគក់ចង្កេះជូន ។ នាងស្តាយព្រោះខ្ញុំ ពុំបានមកឱ្យទាន់ពេលព្រះសង្ឃសូត្រមន្ត ។ សំឡេងនាងរងឹន១ ពីរោះគួរចង់ស្តាប់ ។ ទឹកមុខទៀតសោតក៏ស្រស់ស្រាយ ធ្វើ ឱ្យខ្ញុំមិនហ៊ានមើលមុខនាងចំ ។

- ខ្ញុំមានរឿងមួយចង់ស្នើលោក.... (នាងនិយាយមក កាន់ខ្ញុំ) មិនដឹងថាលោកយល់យ៉ាងម៉េចទេ !

ខ្ញុំងើបមុខមើលនាង នាងញញឹមយ៉ាងស្រស់ ។

- អ្នកនាងមានការអី? មានប្រសាសន៏ចុះកុំទើសទាល់ អ្វី.... ទុកខ្ញុំដូចជាមនុស្សក្នុងគ្រួសារអ្នកនាងទៅចុះ !

- លោកប្រហែលរវល់ណាស់ហើយមែនទេលោក ?



ខ្ញុំសើចតបទៅនាងយ៉ាងមេត្រី :

- មិនរវល់ណាស់ណាទេ ព្រោះរយៈពេលនៃការស្រាវ ជ្រាវនេះនៅយូរទៅទៀត ។ ខ្ញុំទំនេរថ្ងៃរសៀលទាំងអស់ !

- អ្ហូ! ប្រសើរណាស់ ! គឺអ្នកម៉ែនោះអីលោក! (នាង ចង្អុលទៅអ៊ំម៉ែន) គាត់ផ្តើមគំនិតថា ចង់និយាយជាមួយលោក សូមឱ្យលោកជួយបង្រៀនខ្ញុំ នៅពេលដែលទំនេរប្រយោជន៏...

ខ្ញុំងើបមុខយ៉ាងរហ័ស ប៉ះកែវភ្នែកដ៏ថ្លាឆ្វង់របស់នាង ធ្វើឱ្យនាងអាក់សំដីត្រឹមណោះ ។ ខ្ញុំចង់ដឹងឃ្លាបន្តរបស់នាង.. ប្រយោជន៏... អ្វី ? ។ គួរឱ្យស្តាយនាងបន្ត :

- ខ្ញុំចង់រៀនគណិតវិទ្យា និងរូបវិទ្យានៅវិស្សមកាល នេះតើលោកអាចជួយធ្វើជាសាស្ត្រាចារ្យខ្ញុំបានទេ ? បើលោក អនុគ្រោះ ខ្ញុំនឹងមិនបាច់ទៅរៀនឈ្នួលនៅសាលាឯផ្សារទេ !

- តើ អ្នកនាងចង់រៀននៅឯណា ?

- ចា៎ស ខ្ញុំចង់សុំលោកអញ្ជើញមកបង្រៀនខ្ញុំ នៅផ្ទះ ខ្ញុំថ្ងៃនេះតែម្តង ។

សញ្ជឹងគិតមួយសន្ទុះ ទើបខ្ញុំឆ្លើយ ដោយសភាពមិន ដាច់ស្រេចក្នុងចិត្ត :

- ជំរាបអ្នកនាងតាមត្រង់ ខ្ញុំមានការរវល់ច្រើនណាស់ដែរ ក្នុងការសរសេរនិក្ខេបបទនេះ ខ្លាចខ្ញុំមិនអាចបង្រៀនអ្នកនាងឱ្យចប់កម្មវិធីកើត, ព្រោះពេលខ្លីហើយកម្មវិធីវែងផង ។

- បង្រៀនបានប៉ុន្មាន យកប៉ុណ្ណឹងទៅលោក !

និយាយឃ្លានេះចប់ នាងញញឹមយ៉ាងស្រស់, សម្លឹងមុខខ្ញុំ ធ្វើឱ្យខ្ញុំពិបាកនឹងរកពាក្យដោះស្រាយ ។ម្យ៉ាងទៀតខ្ញុំចង់បានសោហ៊ុយខ្លះ ដើម្បីចាយវាយក្នុងរយៈពេលមកស្រាវជ្រាវនេះ ។

នៅស្ងៀមមួយសន្ទុះ ទើបខ្ញុំសម្លឹងនាងដោយមនោសញ្ចេតនារីករាយ ។

- ខ្ញុំរីករាយណាស់ ដោយអ្នកនាងទុកចិត្ត ហើយហៅរកយ៉ាងនេះ, តែពេលវេលាប្រហែលមិនទៀងទាត់នៅពេលខ្លះក៏មិនដឹង ព្រោះចេញពីតំបន់ប្រាសាទមក ខ្ញុំត្រូវដើរអស់រយៈពេលយ៉ាងយូរ ទម្រាំមកដល់ផ្លូវរ៉ឺម៉ក ។ ខ្លាចកិច្ចការលំបាកយឺតយូរយ៉ាងនេះ នាំឱ្យការសិក្សាអ្នកនាងរអាក់រអួលទេដឹង?

នាងសម្លឹងខ្ញុំ ដោយទឹកមុខស្រស់បស់ស្លូតបូត :

- ចាំ ! មិនអីទេ, ចាំខ្ញុំឱ្យគេទៅទទួលលោក ។លោកអាចមកញុាំបាយផ្ទះខ្ញុំក៏បាន ខ្ញុំនឹងធ្វើម្ហូបដោយផ្ទាល់ដៃ ។ពេលយប់លោកអាចនៅគេងផ្ទះម៉ែក៏បាន (នាងចង្អុលទៅ ជូនម៉ែន) គាត់ចូលចិត្តឱ្យលោកនៅគេងដែរ !



- ឱ ! បើបានយ៉ាងនេះ ខ្ញុំសុខចិត្តទទួលសំណើរបស់អ្នកនាងហើយ !

នាងមានទឹកមុខរីករាយ នាងហៅមេដោះនាងឱ្យយកភេសជ្ជៈមកឱ្យខ្ញុំញុាំ រួចនាងនិយាយទៅកាន់យាយ ម៉ែន ដោយទឹកមុខស្រស់ប្រិមប្រិយ :

- ម៉ែ ហាំ ! លោកព្រមទទួលបង្រៀនខ្ញុំហើយ !

ហើយនាងប្រាប់ពត៌មាននេះ ដល់មេដោះនាងទៀតដែលមេដោះញញឹមសម្លឹងខ្ញុំ :

- ចុះលោកគិតថ្លៃឈ្នួលយ៉ាងម៉េចដែរ ចាំ ?

- បាទ ! ខ្ញុំមិនទាន់បានគិតអ្វីសោះទេ ហើយប្រហែលខ្ញុំមិនគិតរហូត... ស្រេចតែអ្នកនាងគិតយ៉ាងម៉េចក៏បានដែរ !

- ចាំ ! អីចឹងក៏បាន ចាំខ្ញុំគិតជូនលោកជាក្រោយ ។

ខ្ញុំក៏ក្លាយខ្លួនជាសាស្ត្រាចារ្យ របស់កញ្ញាដ៏ស្អាតហើយស្លូតនេះ នៅពេលបីថ្ងៃក្រោយមក ។ ភ្នែកទាំងគូរបស់នាង

ធ្វើឱ្យខ្ញុំស្រមៃយ៉ាងច្រើន ។ សំដីទន់ភ្លន់រួសរាយរបស់នាងធ្វើឱ្យខ្ញុំចង់តែនៅជិត និង..... ។

ការសិក្សានេះ បានប្រព្រឹត្តទៅដ៏គួរជាទីពេញចិត្ត ។ សិស្សខ្ញុំមានរូបស្អាតពិតប្រាកដហើយ តែប្រាជ្ញាក៏សក្តិសមនឹងសម្រស់នាងទៀត ។ នាងតែងឆ្លើយសំនួររបស់ខ្ញុំបានសឹងគ្រប់ពេល. បញ្ជាក់ឱ្យដឹងថានាងបានយល់ច្បាស់នូវអ្វីដែលខ្ញុំពន្យល់នាង។ នាងយកចិត្តទុកដាក់គ្រប់នាទី ។ ខ្ញុំយល់យ៉ាងច្បាស់ថានាងសុំឱ្យខ្ញុំមកបង្រៀននេះ ដោយមានបំណងចង់ចេះ ចង់ដឹងពិតប្រាកដ. គ្មានគោលបំណង គ្មានស្រមៃអ្វីក្រៅពីនេះសោះ។ គួរឱ្យសរសើរនាងមែន ឃើញអាកប្បកិរិយានាងរឹងប៉ឹងយ៉ាងនេះ ខ្ញុំបែរជាខ្លាចនាង ហើយគោរពនាងកាន់តែច្រើនឡើង ។

គេចណាស់ បែរជាបានជួបកាន់តែជិត។ ទោះបីព្រលឹងខ្ញុំ កត់ត្រាទុកនូវកំណាព្យស្នេហ៍ ដ៏មានន័យទឹកដមតែឯកឯងនេះក៏ដោយ នៅចំពោះមុខនាង ខ្ញុំខ្វះសេចក្តីក្លាហាននឹងសារ-ភាព ។ ខ្ញុំនៅជាគ្រូម្នាក់ដ៏គំរូ ! តែខ្ញុំតែងលួចដកដង្ហើមវែងៗពេលចិត្តខ្ញុំចង្អៀត ដើមទ្រូងខ្ញុំតឹង ។

# ៣
# អាថ៌កំបាំងនៃរឿងស្នេហា

ប្រហែលដោយសារពីថ្ងៃ ខ្ញុំដើរហាលថ្ងៃក្តៅយូរពេកក៏មិនដឹង បានជាល្ងាចនេះ ខ្ញុំមិនស្រួលខ្លួនចង់គ្រុនបន្តិច ចង់ខ្យល់ចាប់បន្តិច ។

ខ្ញុំបានមកដល់ផ្ទះ **ផូនម៉ែន** តាំងពីថ្ងៃរសៀល គេងទាំងក្រហល់ក្រហាយ ។ ខ្ញុំក្អួតចង្អោរជាច្រើនលើកច្រើនសារ ។ **ផូនម៉ែន** និង **កែវ** ខ្វះខ្វែងឈឺឆ្អាលយ៉ាងច្រើនចំពោះខ្ញុំ ។ **កែវ** ចេញតាមគ្រូពេទ្យ ហើយដាំបបរឱ្យខ្ញុំញុាំ. ច្របាច់ថ្ងាសខ្ញុំនៅពេល ដែលខ្ញុំថ្ងូរថាឈឺក្បាល ។ នាងស្រក់ទឹកភ្នែកយ៉ាងរហ័សពេលខ្ញុំបែរទៅ ឃើញនាងយំអាណិតខ្ញុំ ។ នាងកោសខ្យល់ឱ្យខ្ញុំ. យកប្រេងកូឡារីតសព្វសាច់.... ឱ ! នាងនិងខ្ញុំហាក់ដូចជាស្វាមីភរិយាដូច្នោះ ! ដោយសារកម្លាំងចិត្ត ឬដោយអានុភាពអ្វីមិនដឹង ខ្ញុំបានធូរស្រាលខ្លះហើយ ....

- មិនដឹងបានអ្វី តបស្នងសងគុណកែវទេ (ខ្ញុំនិយាយទៅកាន់នាង) ..... កែវឈឺឆ្អាលនឹងខ្ញុំយ៉ាងនេះ ធ្វើឱ្យខ្ញុំបំភ្លេចគុណ កែវ មិនបានសោះក្នុងមួយជាតិនេះ ។

កែវ ឥតឆ្លើយថាម៉េចសោះ តែនាងញញឹមយ៉ាងស្រស់ចម្លែកមួយ. នាងយកផ្ចិតមកបក់យ៉ាងញាប់ពីលើមុខខ្ញុំ នាងហាក់ដូចជាក្មេងស្រីដ៏ក្រម៉ាចម្នាក់គួរឱ្យស្រឡាញ់ ។ ប្រហែលនាងចង់ប្រឡែងលេង.... តែជាក់ជានាងនឹកថា ស្ងួនពេញក្រមុំហើយ ។ នាងអង្គុយក្បែរខ្ញុំស្ទាបថ្ងាសខ្ញុំ ។ ដៃនាងក្រអូបទន់ត្រជាក់... ខ្ញុំចង់តែចាប់ដៃនាងមកថើប...តែនាងជានារីគួរឱ្យគោរព ។

- លោកគ្រូ(១) ត្រជាក់ច្រើនវិញហើយ ខ្ញុំនៅមាននំជូនលោកគ្រូពិសាទៀត ផ្លែឈើក៏មានដែរ !

ខ្ញុំញញឹមសំដែងការអរគុណដ៏ជ្រាលជ្រៅ :

- គ្មានជំងឺអ្វី អាចស្ថិតនៅក្នុងខ្លួនខ្ញុំបានយូរទេ ព្រោះនៅជិតខ្ញុំមាន កែវ ទៅហើយ ។ កែវ ជាទេពធីតាធ្វើឱ្យមនុស្សទាំងសកលបានសុខ សុខ ...គ្រប់ៗគ្នា ។

---

១ នាងហៅខ្ញុំលោកគ្រូៗចាប់តាំងពីពេលដែលខ្ញុំបានក្លាយជាសាស្ត្រាចារ្យរបស់នាងមក ។



នាងមើលមុខខ្ញុំចំ តែនាងដាក់មុខវិញយ៉ាងរហ័សពេលប្រទះជាមួយកែវភ្នែកខ្ញុំ ។ នាងឱនមុខចុះ... នៅស្ងៀម ។ ក្តីបារម្ភមួយឆាបឡើងក្នុងអារម្មណ៍ខ្ញុំ... ខ្ញុំបារម្ភខ្លាចនាងយល់ថាសំដីខ្ញុំឡែបខាយពុំគប្បីទៅលើនាង ក្នុងប្រការណាមួយ ។ ខ្ញុំដកដង្ហើមធំ :

- កែវ ... !

នាងងើបមុខឡើង. ឆ្លើយស្ទើរមិនចង់ឮ :

- ចាំស !

- ទោះបីពេលនេះ ឬទៅថ្ងៃមុខ ខ្ញុំមានពាក្យអ្វីឆ្គងដែលខ្ញុំមានចំពោះ កែវ សូម កែវ កុំនឹងខ្ញុំណា !

នាងគ្រវីក្បាល

- លោកគ្រូមិនដែលមានប្រសាសន៍អ្វី មិនគប្បីចំពោះខ្ញុំទេ ខ្ញុំស្គាល់ចិត្តលោកគ្រូណាស់ !

ខ្ញុំសើចយ៉ាងឥតន័យ មិនដឹងជានាងនិយាយនេះដោយសុទ្ធចិត្តឬយ៉ាងណាទេ ។ នាងស្គាល់ចិត្តខ្ញុំ... ឬមួយនាងដឹងថាខ្ញុំលំបាកចិត្តយ៉ាងណាៗ ដែរចំពោះនាង ?

- យប់បន្តិចហើយ ! កែវ ទៅគេងចុះ ! ខ្ញុំបានស្រាក

ស្បៀយបន្តិចហើយ ខ្ញុំអាចជូន **កែវ** ទៅផ្ទះវិញបាន ។

ខ្ញុំច្រត់ដៃបម្រុងក្រោក ។ តែនាងទាញស្មាខ្ញុំឱ្យគេងទៅវិញ :

- កុំបារម្ភដល់ខ្ញុំថ្មី ! ខ្ញុំនៅគេងជាមួយម៉ែទីនេះដែរ... យប់នេះ ! ខ្លាចក្រែងលោក មានការមិនស្រួលនៅពេលយប់ព្រលប់ ។

- ឱ ! **កែវ** មានចិត្តសន្ដោសដល់ខ្ញុំធំធេងណាស់ ! ពុំដែលមានអ្នកប្រណីដល់ខ្ញុំដូច **កែវ** ទេ !

- គឺជាការយល់ទុក្ខធុរៈគ្នា ទៅវិញទៅមកទេតើ ! លោកគ្រូបានខំបង្រៀនខ្ញុំ ឱ្យខ្ញុំមិនខ្វល់នឹងលោកគ្រូម៉េចនឹងកើត ?

ខ្ញុំសើច :

- កូនសិស្ស !

នាងសើចដែរ ។

- ខ្ញុំចង់សួរលោកគ្រូមួយ....

- បាន សួរចុះ ! បើខ្ញុំទាល់ឆ្លើយពុំរួច ខ្ញុំសុំពេលបន្តិចទៅបើកគម្ពីរមើលសិន......



នាងសើចទៀត......យ៉ាងស្រស់គួរភិសម័យ ។

- មិនមែនសួររឿងរៀនសូត្រទេ! គឺខ្ញុំឆ្ងល់ពេលលោកគ្រូនៅម្នាក់ឯង. បើសិនជាមានជម្ងឺដូច្នេះ តើមានអ្នកណាជួយហុចទឹកក្ដៅ ទឹកត្រជាក់ ?

- អូ! មុខតែគេងត្រាំត្រែងទាល់តែជាឯងៗហ្នឹង? បើមិនជាទេ ស្រួលមិនស្រួលខ្ញុំលដកដង្ហើមប៉ុណ្ណឹង ។ តែទេវតាប្រណីដល់ខ្ញុំណាស់ មិនឱ្យខ្ញុំស្លាប់មុនពេលដែលខ្ញុំបានមកស្គាល់ **កែវ** ដ៏មានចិត្តសប្បុរសទេ !

- លោកគ្រូពូកែសំដីណាស់ ! តបស្នងនឹងសំដីដ៏ពិរោះរបស់លោកគ្រូ ខ្ញុំនឹងជូនរង្វាន់លោកគ្រូ ខ្ញុំទៅឆុងទឹកដោះគោជូនលោកគ្រូពិសា ហើយខ្ញុំមានផ្លែទឹកដោះ. ម៉ាក់ប្រេង ម៉ាក់ប្រាំងជូនលោកគ្រូទៀត !

- អរគុណ **កែវ** ណាស់ !

នាងរហ័សក្រោកទៅបាត់ ។ ខ្ញុំងើបឡើងសម្លឹងតាមបង្អួច ដែលបើកទៅរកស្ទឹង ។ ខ្ញុំសម្លឹងរហាត់ទឹក ដែលវិលយឺតៗ មិនចេះឈប់ឈរ ។ អាកាសពីរថ្ងៃនេះ ស្ងប់ស្ងាត់ល្អណាស់ ។ តាមចាស់ៗថា កាលបើពាក់កណ្ដាលខែស្រាពណ៍នេះ

ពុំសូវភ្លៀងទេ. ដល់ពេលភ្ជុំនិងមានភ្លៀងធ្លាក់ជោគជាំជាមិនខាន ។

ធម្មជាតិរីកស្រស់ញញឹម ។ ទឹកស្ទឹងសៀមរាបមិនសូវហូរខ្លាំងប៉ុន្មានទេ ព្រោះមានរបាត់ទឹកច្រើនសង្កាត់ច្រើនជាន់ទប់ពីលើមក ។ ខែវះចាំងលើផ្ទៃទឹកភ្លឺផ្លេក១គួរចង់ទស្សនា...

ធម្មជាតិអើយ អ្នកដឹងចិត្តខ្ញុំខ្វល់យ៉ាងណាទេ ?

ឱ ព្រហ្មលិខិត ! អ្នកនាំខ្ញុំបានស្គាល់កញ្ញាតូចស្រស់ជាបុប្ផាក្រអូប នៃទឹកដីសៀមរាបនេះ តែម្តេចក៏ចាំបង្កើតឱ្យខ្ញុំមានកង្វល់ច្រើនម្ល៉េះទៅលើនាង ?

ខ្ញុំនេះជាអ្នកណា ? រសាត់ទៅណាទៀត ? ហើយម៉េចក៏មកទើនៅទីនេះ ។ ស្រីកែវ នេះជាអ្នកណា ? ស្គាល់ខ្ញុំពីកាលណា ? ម្តេចក៏នាងល្អចំពោះខ្ញុំម្ល៉េះ ? ម្តេចក៏ខ្ញុំគិតទៅលើនាងច្រើនម្ល៉េះ ? ចៃដន្យអាក្រក់ណាស់ ! ធ្វើឱ្យខ្ញុំស្គាល់នាង ! ឱ្យខ្ញុំលួចស្រឡាញ់នាង....រូចខ្ញុំមិនហ៊ានសារភាព សមនាងជាអ្នកមានគុណមកលើខ្ញុំផង ស្នេហាខ្ញុំមិនដឹងជាចេញមកពីច្រកណាហើយទៅចប់នៅឯណាទេ !

មុននេះបន្តិច នាងសួរខ្ញុំថា បើឈឺដូច្នេះ បានអ្នកណាជួយថែនៅពេលខ្ញុំនៅម្នាក់ឯង ! ម្តេចក៏នាងសួរដូច្នេះ ? ក្នុងន័យអ្វីទៅ ? សំណៅ "កម្រងជីវិត " ដែលខ្ញុំសរសេរផ្ទាល់ដៃហើយដែលនាងខ្ចីយកទៅអាន. តើនាងអានចប់ហើយឬនៅ ? បើនាងអានចប់ហើយ នាងក៏អាចស្គាល់ខ្ញុំ ជាមនុស្សបែបណាហើយ ហើយម៉េចចាំសួរខ្ញុំអីចឹងហ្ន៎? គួរឱ្យអស់សំណើចមែន ! ខ្ញុំស្រឡាញ់នាង. តែខ្ញុំចង់ឱ្យនាងដឹងទាំងអស់នូវរឿងរ៉ាវរបស់ខ្ញុំ ដែលអាក្រក់ផុតលេខក៏មាន. អាក្រក់មធ្យមក៏មាន...ហើយក្នុងជីវិតខ្ញុំនេះ គ្មានអ្វីល្អផុតលេខនោះទេ ។ ខ្ញុំចង់ឱ្យនាងដឹងរឿងរ៉ាវទាំងល្អទាំងអាក្រក់នោះ ប្រយោជន៍នាងគិតគន់ទៅថា បើខ្ញុំជាមនុស្សធុននេះ តើនាងអាចរាប់អានខ្ញុំ ហើយយល់យ៉ាងណាខ្លះមកលើរូបខ្ញុំ ? នេះជាដំណើរស្ទង់ចិត្តមួយ ដូចជាដំណើរផ្សងព្រេងក្នុងរូងភ្នំ. ចង់ដឹងថានឹងជួបអ្វីខ្លះ ក្នុងរូងភ្នំនោះ ?

កែវ លើកថាសផ្លែឈើ និងទឹកដោះគោមកដល់ ។

នាងហុចខ្ញុំមួយកែវ ហើយនាងញ៉ាំមួយកែវដែរ ។ នាងទាញ កៅអីអង្គុយក្បែរខ្ញុំ. បែរមុខទៅកាន់ស្ទឹង :

- អាកាសល្អណាស់ហ្ន៎ !

- ល្អណាស់កែវ! អាកាសស្ងប់ស្ងៀមយ៉ាងនេះខ្ញុំសង្វេគខ្លួន ស្រណោះស្រណោកដល់ស្រុកទេស, ដល់គ្រូបាធ្យាយ ដល់អតីតកាលខ្ញុំនៅឯនាយព្រំដែន....វាហាក់ដូចជានៅថ្មីៗនេះឯង ទោះបីយូរឆ្នាំកន្លងមកហើយក៏ដោយ ! ....

- ឱ !

របូតមាត់តែពាក្យ "ឱ" ប៉ុណ្ណោះនាងនៅស្ងៀមទៅ ។ នាងសម្លឹងទៅលើផ្ទៃទឹកស្ទឹង, តែទឹកភ្នែកនាងហូរថ្លាឆ្វង់មកលើថ្ពាល់ដ៏ល្អរបស់នាង ។ ខ្ញុំស្រឡាំងកាំង ដោយមិនយល់រឿងហេតុសោះ ។ នាងយំរឿងអី ? ខ្ញុំសួរនាងដោយសម្លេងញ័រៗថា :

- មានរឿងអីឬ កែវ ?

នាងប្រញាប់ជូតទឹកភ្នែក ហាក់ដូចមិនចង់ឱ្យខ្ញុំយល់នូវជម្រៅចិត្តនាង :

- ខ្ញុំគិតថាជីវិតលោកគ្រូ, មិនខុសពីជីវិតខ្ញុំទេ, យើងសុទ្ធតែជាកូនកំព្រាដូចគ្នា ! (នាងឈប់ស្ងៀមបន្តិច... ហើយបន្តទៅទៀត) ម្សិលមិញ ខ្ញុំបានអានចប់ <<កម្រងជីវិតខ្ញុំ>> ដែលលោកគ្រូសរសេរនោះ ខ្ញុំមិនទាន់ស្មានថាជារឿងពិតទេ,



តែអតីតកាលនៅឯនាយព្រំដែន, ខ្ញុំក៏នឹកឃើញរឿងនោះឡើងវិញទាំងអស់ ហើយក៏ជឿថារឿងនោះជារឿងពិតរបស់លោកគ្រូ ។

ខ្ញុំមានភាពតានតឹងក្នុងចិត្តជាខ្លាំង ។ តែដោយខ្ញុំមានបំណងចង់ឱ្យនាងដឹងរឿងខ្ញុំដែរ ខ្ញុំទ្រាំនិយាយទាំងលំបាកថា :

- ចុះកាលមុន កែវ យល់យ៉ាងម៉េចទៅវិញ ?

- ខ្ញុំស្មានថា លោកគ្រូក៏ដូចជារឿងអ្នកនិពន្ធឯទៀតដែរ, ចូលចិត្តប្រឌិតរឿង ។ ម្យ៉ាងទៀត រឿងលោកគ្រូមានលក្ខណៈឃោសនានយោបាយផង !

- មិនមែនទេ កែវ ! ខ្ញុំសរសេររឿងនោះតាមដំណើរដែលមានកើតសុទ្ធសាធ !

- បើដូច្នេះមែន ព្រះគ្រូថាច់កៅ ...

និយាយបានត្រឹមនេះ នាងក៏ឈប់ស្ងៀម ។ ខ្ញុំបន្តឃ្លាដែលមិនចប់របស់នាង :

- ព្រះគ្រូថាច់កៅ បានបង្ហាត់បង្រៀនខ្ញុំ តាំងពីខ្ញុំទើបនឹងដឹងក្តីមកម្ល៉េះ ។ លោកស្រឡាញ់ខ្ញុំ, លោកលាតត្រដាងពីប្រវត្តិសាស្ត្រខ្មែរ កលយុគផ្សេងៗ នៅកម្ពុជាក្រោមប្រាប់ខ្ញុំ ។

គឺចាប់តាំងពីពេលនោះមក ខ្ញុំទទួលការអប់រំពីរឿងជាតិ រឿងប្រទេសនិងរឿងប្រជាជន។ គឺចាប់តាំងពីពេលនោះមកហើយ ដែលខ្ញុំមានគំនិត ចង់បានសិទ្ធិសេរីភាព ឯករាជ្យ វឌ្ឍនភាព សុភមង្គល... ។ ខ្ញុំសូមលំអោនចិត្តដោយគោរពចំពោះលោកគ្រូខ្ញុំនេះ ដែលឥឡូវលោកសុគតទៅហើយ ។ ពួកយួនចាប់លោកទៅឃុំឃាំងក្នុងជង្រុកមួយ ឡូកឡំជាមួយខ្មែរប្រុសស្រី ក្មេងចាស់ជាច្រើន ហើយដុតជង្រុកនេះទៅ ....។ គួរឱ្យខ្លោចផ្សាណាស់....យួនសម្លាប់លោកគ្រូខ្ញុំមែន, សម្លាប់ខ្មែរក្រោមអស់ជាច្រើនមែន, តែខ្ញុំមិនទាន់ស្លាប់ទេ... ខ្ញុំនឹងបន្តការតស៊ូដើម្បីឯករាជ្យដែនដីកម្ពុជាក្រោមនេះទៀត ! ...

ខ្ញុំនិយាយចប់ នាងដកដង្ហើមធំ :

- បើដូច្នេះ ម្សិលមិញខ្ញុំអានចប់ហើយខ្ញុំយំ មិនខាតទឹកភ្នែកទេ ព្រោះរឿងលោកគ្រូ ជារឿងមួយដែលខ្មែរត្រូវយំ ហើយត្រូវចងកំហឹង !

- ខ្ញុំគ្មានសង្ឃឹមថា មានអ្នកណាយំជាមួយខ្ញុំទេ, ព្រោះខ្មែរយើងខាងកណ្ដាលឯណោះ កំពុងតែសប្បាយនឹងស្រុកសុខសាន្ត, មិនអាចជឿថា មានខ្មែរមួយចំនួន កំពុងរស់ក្នុងស្ថាននរកឯណោះទេ ។



សង្គមខ្មែរសព្វថ្ងៃ កំពុងរស់នៅក្នុងអត្ត-ទត្តភាព, គ្មានគិតដល់នរណាក្រៅពីខ្លួនឯងទេ ។ ម្យ៉ាងទៀតខ្មែរកំពុងដើរជាន់ដានចាស់ ដោយសប្បាយនឹងប្រាក់កាសដែលគេយកមកទាក់, សប្បាយនឹងស្រី, ស្រា, ល្បែង.....ដែលនាំឱ្យខ្មែរកណ្ដាល អាចវិនាសទៅទៀត.... នឹកទៅ ឈឺចាប់ណាស់ **កែវ** អើយ ! ខ្ញុំស្មានមិនដល់ថា មាន **កែវ** ម្នាក់ដែរ ដែលបានយល់ខ្ញុំ, ហើយអាណិតខ្ញុំ, អាណិតខ្មែរឯនាយព្រំដែន ។

នាងសម្លឹងខ្ញុំ ហើយតបយ៉ាងរហ័ស :

- លោកគ្រូគិតខុសហើយ ! លោកគ្រូឈឺចាប់, លោកគ្រូត្រូវតែឱ្យគេដឹងសិន ទើបដឹងថាគេអាណិតលោកគ្រូ ឬមិនអាណិត។ ឯនេះ, លោកគ្រូមិនទាំងផ្សាយរឿងឈឺចាប់នេះផង ធ្វើម្ដេចគេដឹងនឹងជួយឈឺឆ្អាល ?

- ព្រោះខ្ញុំបានសង្កេតឃើញខ្មែរឯណោះ ខ្ញុំក៏យល់យ៉ាងហ្នឹងទៅ !

- បើអីចឹងបានន័យថា លោកគ្រូស្មានខុសស្រេចទៅហើយ ! ព្រោះគ្រាន់តែអានការកត់ត្រារបស់លោកគ្រូភ្លាម ខ្ញុំអាណិតលោកគ្រូ និងខ្មែរនៅឯណោះភ្លាមដែរ ។ លោកគ្រូ

ឃើញទេ ? ខ្ញុំនេះជាកូនខ្មែរទីមួយដែលបានអានភ្លាមអាណិតភ្លាម ។ ចុះទម្រាំបើខ្មែរឯទៀតៗ បានអានគ្រប់គ្នា តើនៅមានខ្មែរប៉ុន្មាននាក់ទៀត នឹងជួយអាណិតលោកគ្រូ ហើយជួយចងគំនុំជាមួយសត្រូវយួន ?

- ទេ កែវ ! រឿងបែបនេះ មានយូរអង្វែងណាស់មក ហើយកើតឡើងតៗគ្នាហូរហែនៅកម្ពុជាក្រោម ដែលខ្មែរទាំងអស់ត្រូវតែដឹង ត្រូវតែឮគ្រប់ៗគ្នា !

កែវ នៅស្ងៀម ប្រហែលជានាងយល់ស្របដូចខ្ញុំដែរក៏មិនដឹង ។ ខ្យល់តឹងមួយ បោកបក់មកលើវិញ្ញាណខ្ញុំ កាលណាខ្ញុំនឹកដល់រឿងខាងលើនេះឡើង ធ្វើឱ្យខ្ញុំកើតទុក្ខជាទម្ងន់ ។ សួរមាត់កែវបន្តទៅទៀតថា :

- ចុះបងប្អូនស្រុកកំណើត និងអ្នកស្រុកលោកគ្រូយ៉ាងណា ? មានលក្ខណៈដូចម្ដេច ?

ពាក្យសួររបស់នាង ធ្វើឱ្យខ្ញុំមានចិត្តរំភើបក្រៃលែង ក្បិតនាំឱ្យខ្ញុំ នឹករលឹកដល់ស្រុកកំណើត និងរឿងរ៉ាវរបស់ខ្ញុំ ហើយខ្ញុំចង់និយាយឱ្យគេដឹងឮផងដែរ ជាពិសេស កែវ កញ្ញាស្រស់ល្អនេះ ។ ភ្នែកមើលត្រង់ទៅមុខ ដកដង្ហើមធំនិយាយ



ដោយសម្លេងស្មើថា :

- រំលឹករឿងខ្ញុំ ធ្វើឱ្យខ្ញុំអាប់អួក្នុងចិត្តពេកណាស់ ។ ស្រុកកំណើតខ្ញុំនៅក្នុងកម្ពុជាកណ្ដាលឯណោះទេ តែនៅឯជាយដែនជិតកម្ពុជាក្រោម គឺនៅខាងស្រុកគិរីវង្សខេត្តតាកែវយើងនេះ។ ខ្ញុំកើតក្នុងត្រកូលអ្នកមានសម្បត្តិដ៏រុងរឿង ។ ម្ដាយខ្ញុំអនិច្ចកម្មយូរហើយ. ឯឪពុកខ្ញុំមានស្រែរាប់ពាន់ហិកតា. គោក្របី សេះអំពែរាប់ម៉ឺន មានកូនបំណុលរាប់ពាន់នាក់ ដែលកូនបំណុលខ្លះ នៅឯនាយព្រំដែននោះទៀត ។ ខ្ញុំបានរៀនសូត្រនៅថ្នាក់បឋមសិក្សានៅឡើយ ឪពុកខ្ញុំមានអាពាធជាទម្ងន់ ហើយក៏បានអនិច្ចកម្ម នៅពេលកន្លះខែក្រោយមក ក្រោយពីបានចែកទ្រព្យសម្បត្តិដល់ខ្ញុំ និងបងៗខ្ញុំបីនាក់ទៀត ។ បងខ្ញុំទាំងបីច្រណែនគ្នា មិនពេញចិត្តនឹងទ្រព្យចំណែកនេះទេ ហើយម្នាក់ចេញទៅលិច ខ្លះចេញទៅកើត ប្ដឹងប្ដល់គ្នា ។ ឃើញដូច្នេះ. ថ្ងៃមួយដែលខ្ញុំបានជួបព្រះគ្រូ ថាច់ កៅ និមន្តមកពីកម្ពុជាក្រោម ខ្ញុំក៏លួចរត់ទៅតាមលោក ចោលទ្រព្យសម្បត្តិជាចំណែករបស់ខ្ញុំ ចោលបងប្អូនខ្ញុំ ។ នឹកទៅ គួរឱ្យខ្មាសគេណាស់ ខ្មែរយើងមានដីទូលំទូលាយត្រូវខ្លាំងបរទេសលេបយក

ជិតអស់ទៅហើយ ខ្មែរកណ្ដាលឯណោះ គិតតែប្ដឹងប្ដល់គ្នាពីរឿងចែកដីធ្លីគ្នាទៅវិញ ។ ខ្ញុំប្ដេជ្ញាថា តែប៉ុណ្ណោះខ្ញុំនឹងដើរផ្សងព្រេងនៅឯកម្ពុជាក្រោម ត្រាតែអស់ជីវិត. ខ្ញុំមានគំនិតមួយថាទ្រព្យសម្បត្តិនេះជាចំណងមួយអាក្រក់អាក្រីណាស់ ជាពិសេសទ្រព្យសម្បត្តិជាកេរអាករនេះឯង ហើយខ្ញុំសច្ចាថាត្រូវតែរកសម្បត្តិ ដោយកម្លាំងនិងសមត្ថភាពខ្លួនឯងផ្ទាល់វិញ ។ ហ៊ឹស ! រឿងខ្ញុំនេះបែបបែកបន្តិចហើយ. កែវ កុំឆ្ងល់អី ទោះបីជាតិនេះខ្ញុំក្រ ក៏គង់មានខ្មែរខ្លះក្រជាងខ្ញុំ ដែលគ្មានអ្វីសោះទៅទៀត ។ ព្រះគ្រូ ថាច់ កៅ បានផ្ដុងផ្ដើមខ្ញុំឱ្យរៀនអក្សរបារាំងនៅសាលាយួន ហើយរៀនពីពង្សាវតារនិងអរិយធម៌ខ្មែរនៅឯវត្ត រហូតដល់ខ្ញុំជាប់មធ្យមសិក្សាប័ត្រយួន ។ ព្រះគ្រូបានផ្ដុងផ្ដើមខ្ញុំឱ្យមកបន្តការសិក្សានៅឯភ្នំពេញ ហើយខ្ញុំអាចយកសញ្ញាប័ត្រនៅភ្នំពេញបានទៀត ។ ដោយខ្ញុំរំភើបនឹងអ្វីៗ ជាវត្ថុសិល្បៈខ្មែរ.. ខ្ញុំក៏ចូលរៀននៅមហាវិទ្យាល័យបុរាណវិទ្យា ហើយមានវាសនាមកជួប កែវ ដូចថ្ងៃនេះ ....

កែវ ដកដង្ហើមធំ ។ យប់កាន់តែជ្រៅ ខ្យល់ត្រជាក់ ។ កែវ ពុំទាន់ទៅណាចោលខ្ញុំទេ ឯខ្ញុំក៏បានត្រជាក់ចិត្តដែរកាល



ណាបាននៅជិត កែវ .... មើលមុខ កែវ ។

- រឿងលោកគ្រូវែងអន្លាយណាស់.....

- វែងមែន ! ខ្ញុំបានស្គាល់អ្នកស្រុកនៅឯនាយព្រំដែនច្បាស់លាស់ណាស់ គេស៊ូរាល់ថ្ងៃដើម្បីឱ្យប្រយោជន៍ដើមរបស់គេនៅគង់វង្ស ឱ្យអរិយធម៌ខ្មែរនៅរស់.... គេមានសាមគ្គីភាពយ៉ាងអង់អាច ដែលជាខ្លឹមសារនៃការតស៊ូនេះ ព្រោះបើគេគ្មានសាមគ្គីភាពទេ ប្រហែលយួនរំលាយជាតិខ្មែរ នៅកម្ពុជាក្រោមបាត់អស់ទៅហើយ !

យើងនៅស្ងៀមយ៉ាងយូរ ។ ខ្ញុំនឹកថា ល្ងាចនេះតើនឹងត្រូវសារភាព រឿងស្នេហាដ៏ស្មុគស្មាញនេះឱ្យហើយទៅឬយ៉ាងណា ត្រូវចាប់និយាយអំពីអ្វីមុន ? គួរឱ្យពិបាកមែន ។

តែ កែវ ចាប់បន្តទៀតថា :

- ខ្ញុំមើល"កម្រងជីវិតខ្ញុំ"របស់លោកគ្រូ. ខ្ញុំបានស្គាល់ស្រីម្នាក់គឺនាងរីណា តើនាងទៅណាហើយឥឡូវនេះ ?

- បាទ ! ខ្ញុំទើបនឹងបានដំណឹងថា សព្វថ្ងៃនាងនៅស្រុកបារាំង ព្រោះនាងបានប្ដីបារាំងតាំងពីពេលបែកពីខ្ញុំម្ល៉េះ ! នាងបានសុខហើយ !

នាងនៅស្ងៀម ។ ខ្ញុំមើលនាងពីរបីដង ទម្រាំផ្ដើមនិយាយថា :

- កែវ ?

នាងងើបមុខឡើង. ភ្នែកនាងទាំងគូថ្លាឆ្វង់ មើលចំមុខខ្ញុំ :

- ចាំស !

ដកដង្ហើមធំចោលមួយ ....... ខាំធ្មេញ ។ ខ្ញុំដាក់ចិត្តនិយាយថា :

- បើសិនខ្ញុំជាលា កែវ ទៅឆ្ងាយ..... តើ កែវ នឹកដល់ខ្ញុំខ្លះទេ ?

នាងងើបមើលមុខខ្ញុំម្ដងទៀតយ៉ាងរហ័ស ។ ទឹកមុខនាងហាក់ដូចជាជំពប់នូវរឿងមួយដ៏បារម្ភ....

- លោកគ្រូអញ្ជើញទៅណា ?.... ខ្ញុំជឿថា លោកគ្រូនឹងបានសុខក្នុងចិត្តជាច្រើន នៅទឹកដីសៀមរាបនេះ.... ដែលមានសិល្បៈវប្បធម៌ដ៏ជាទីស្រឡាញ់របស់លោកគ្រូ .... ហើយនិងមាន....

នាងឈប់ស្ងៀមត្រឹមណោះ ។ ខ្ញុំរបូតមាត់បន្តថា :



- នាង កែវ ផងដែរ !

នាងធ្វើព្រងើយ ហាក់ឥតឮពាក្យចុងក្រោយរបស់ខ្ញុំទេ តែទឹកមុខនាងស្រទន់ចម្លែក ....... នាងមើលត្រង់ទៅមុខ ។ អាកប្បកិរិយា ព្រងើយកន្ដើយរបស់នាង ធ្វើឱ្យខ្ញុំចាប់ចិត្តជាខ្លាំង !

- កែវ ?

- ចាំស !

- ខ្ញុំមិនចង់ឃ្លាតពីទឹកដីនេះដែរ ..... តែធ្វើម៉េច កែវ អើយ ! នៅឯកម្ពុជាក្រោម ខ្ញុំភ្ជាប់ពាក្យជាមួយកញ្ញាម្នាក់ ហើយនិងសន្យាថានឹងរៀបការជាមួយនាង! ពេលណាខ្ញុំបញ្ចប់ការសិក្សានៅឯមហាវិទ្យាល័យ ....

នាងកំរើកខ្លួន ។ ចិញ្ចើមគួចចូលគ្នា... នាងចង់យំ :

- លោក....គ្រូ....

ខ្ញុំមើលមុខនាងចំ.... ងក់ក្បាល :

- ចាស់ៗ បានព្រមព្រៀងឱ្យនាងនិងខ្ញុំ ដើរផ្លូវរួមជីវិតហើយ ។ បែកពីកែវ ... គួរឱ្យខ្ញុំរន្ធត់ណាស់ !

នាងស្រក់ទឹកភ្នែក ។